# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## ក្រោមប្រធានបទ៖ ពាក្យខ្មែរថា «បាចអង្កាមច្រាសខ្យល់» និងពាក្យថា «ឈាមស្រែកស្បែកហៅ» ។

**Website: www.hoksavann.org**

ថ្ងៃទី២១ មិថុនា ២០១០



ពាក្យថា «បាចអង្កាមច្រាសខ្យល់» មានពាក្យបី គឺបាច១ អង្កាម១ និងច្រាសខ្យល់១ ។ អង្កាម គឺជាសំបករបស់ស្រូវដែលគេកិនហើយអុំចោលជាវត្ថុស្ដើងស្រាល ។ បាច គឺគ្រវែងទៅ ឬចោលទៅ ។ ច្រាសខ្យល់ គឺបាចបញ្ច្រាសទិសខ្យល់ បើខ្យល់បក់មកពីទិសខាងត្បូងតម្រង់ទៅទិសខាងជើង អ្នកបាចអង្កាម បាចពីទិសខាងជើងតម្រង់ទៅទិសខាងត្បូង អង្កាមនោះពុំអាចមានសន្ទុះទៅមុខបានឡើយ រមែងហើរត្រឡប់មករកម្ចាស់អ្នកបាចវិញ ។ ពាក្យនេះមានន័យសេចក្ដីប្រៀបធៀបមកអ្នកធ្វើអំពើអាក្រក់ អំពើអាក្រក់នោះរមែងត្រឡប់ឲ្យផលដល់អ្នកធ្វើវិញ ។ មួយទៀត អំពើអាក្រក់ដែលគេប្រព្រឹត្តទៅលើជនណាម្នាក់ដែលជាជនឥតទោស អំពើអាក្រក់នោះនឹងត្រឡប់ឲ្យផលអាក្រក់ដល់ខ្លួនអ្នកប្រព្រឹត្តវិញ ។ បានសេចក្ដីថា អំពើអាក្រក់គ្រប់យ៉ាងដែលគេបានធ្វើហើយ តែងផ្ដល់ផលដល់អ្នកប្រព្រឹត្តវិញជាដរាប ។ អំពើអាក្រក់ដែលគេប្រព្រឹត្តទៅលើជនម្នាក់ បាបនោះមានទំហំតូច តែបើប្រព្រឹត្តទៅលើជនច្រើនគ្នា បាបនោះមានទំហំធំ ។ បាបមានទំហំធំបែបនេះ ច្រើនអ្នកមានអំណាចប្រព្រឹត្តទៅលើប្រជាពលរដ្ឋរបស់ខ្លួន ។ ហេតុយ៉ាងណា ផលយ៉ាងនោះ ឬកម្មបែបណា ផលបែបនោះ នេះជាពាក្យរបស់ព្រះពុទ្ធសាសនា ។ បានសេចក្ដីថា អំពើអាក្រក់ក្ដី ល្អក្ដី គេនឹងទទួលផលនៃអំពើនោះតាមទំហំនៃអំពើរបស់ខ្លួន ។ ដូចជាតុលាការដែលមានយុត្តិធម៌នៃផ្លូវអាណាចក្រ ក៏គេកាត់សេចក្ដីឲ្យមានទោសធ្ងន់ស្រាលតាមកំហុសរបស់អ្នកប្រព្រឹត្ត យោលតាមច្បាប់របស់រដ្ឋនីមួយៗ ។ ដូច្នេះពាក្យថា «បាចអង្កាមច្រាសខ្យល់» អង្កាមរមែងត្រឡប់មកដល់អ្នកបាចវិញ ជាពាក្យបង្ហាញស្របតាមផ្លូវធម៌និងផ្លូវលោកថា បើគេប្រព្រឹត្តអាក្រក់ គេនឹងទទួលផលអាក្រក់ ។ អត្ថន័យផ្លូវធម៌ មានន័យពិសេសជាងផ្លូវលោក ត្រង់អំពើអាក្រក់និងអំពើល្អ ទោះការប្រព្រឹត្តនោះគ្មានគេឃើញនិងដឹងឮក៏ដោយ ក៏ត្រូវទទួលផលនៃអំពើអាក្រក់នោះនៅពេលណាមួយពុំខានឡើយ ។ ចំពោះតុលាការដែលកាត់សេចក្ដីមិនប្រកបដោយយុត្តិធម៌ ដោយលំអៀង ព្រោះស្រឡាញ់ ព្រោះស្អប់ ព្រោះភ័យខ្លាច និងព្រោះល្ងង់ អ្នកកាត់សេចក្ដីដែលមិនប្រកបដោយយុត្តិធម៌នោះ នឹងទទួលផលអាក្រក់មកខ្លួនវិញ ។

ពាក្យថា «ឈាមស្រែកស្បែកហៅ» ជាពាក្យរបស់ចាស់បូរាណខ្មែរ ស្របនឹងព្រះពុទ្ធសាសនាថា អ្នកដែលសាងបាបកម្មធ្ងន់ៗ មានការប្រហារជីវិតមនុស្សជាដើម បាបនោះនឹងស្រែកហៅបុគ្គលនោះឲ្យមកទទួលផល ។ មួយទៀតអ្នកដែលបំផ្លាញជីវិតគេ អ្នកនោះនឹងទទួលការសងសឹកវិញ ឈាមសងឈាម ជាពិសេសជនពាលប្រព្រឹត្តអំពើឧក្រិដ្ឋមកលើអ្នកមានគុណធម៌ខ្ពស់ ជនពាលនោះនឹងទទួលផលនៃអំពើបាបក្នុងបច្ចុប្បន្នទាន់ហន់ ។ នៅក្នុងធម្មបទនៃគម្ពីរព្រះពុទ្ធសាសនាមានដំណាលថា ព្រះមោគ្គលានបានសំរេចជាព្រះអរហន្តថែមទាំងមានឫទ្ធិទៀតផង តែត្រូវចោរវាយធ្វើគតរហូតដល់រលត់ខន្ធបរិនិព្វាន ដោយទោសដែលលោកបានធ្វើឃាតមាតាបិតារបស់លោកកាលពីជាតិមុន គឺឈាមរបស់អ្នកមានគុណបានស្រែកហៅរកលោកដើម្បីដាក់ទោស ។ យ៉ាងណាមិញជនពាលដែលសម្លាប់មនុស្សដោយការចងគំនុំធម្មតាក្ដី ដោយផ្លូវនយោបាយក្ដី ត្រូវឈាមនិងស្បែករបស់អ្នកដែលគេសម្លាប់ ស្រែកហៅដោយការឈឺចាប់ ឲ្យទទួលការឈឺចាប់ដូចគ្នា ។ វាលពិឃាតរបស់ខ្មែរក្រហមដែលមានបរទេសនៅពីក្រោយ បានសម្លាប់ពលរដ្ឋខ្មែរយ៉ាងសាហាវព្រៃផ្សៃបំផុត ដែលប្រវត្តិសាស្ត្រពិភពលោកពុំដែលកើតមាន ។ អ្នកដែលសាងបាបកម្មដ៏សាហាវនេះ នឹងគេចមិនផុតអំពីការទទួលផលបាបដែលខ្លួនបានសាងឡើយ គឺឈាមស្រែកហៅតុលាការអន្តរជាតិឲ្យជួយរកយុត្តិធម៌ឲ្យខ្លួន ហើយពួកឧក្រិដ្ឋនេះស្លាប់ទៅ នឹងធ្លាក់ទៅសោយទុក្ខក្នុងនរកដូចគេច្រានទម្លាក់ ។

ពាក្យថា «បាចអង្កាមច្រាសខ្យល់» និងពាក្យ «ឈាមស្រែកស្បែកហៅ» ជាពាក្យបូរាណខ្មែរទាក់ទងនឹងព្រះពុទ្ធសាសនា ដែលមានអត្ថរសប្រៀនប្រដៅថា អំពើបាបគ្រប់យ៉ាងដែលគេបានប្រព្រឹត្តទៅលើអ្នកដទៃ ដែលមានលក្ខណៈរំលោភសិទ្ធិមនុស្ស អំពើបាបនោះនឹងផ្ដល់ផលឲ្យអ្នកប្រព្រឹត្តវិញ ពុំអាចគេចផុតឡើយ ដូច្នេះត្រូវជៀសវាងកុំប្រព្រឹត្តអំពើអាក្រក់គ្រប់យ៉ាង ទោះបីអំពើអាក្រក់មានភាពតិចតួចក៏ដោយ ។៚

❄ ❄

❄